# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...១៥០.អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់វិទ្យាស្ថានប្រាយហូប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក. ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ៤០៣៣ អយក.ឧស. ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៧

## ស ម្រេ ច

**មាត្រា ១ :** ទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **វិទ្យាស្ថានប្រាយហូប** ( **Bright Hope Institute** ) សរសេរកាត់ជាភាសាខ្មែរ **វ.ប.ហ** និងសរសេរកាត់ជាភាសាអង់គ្លេស " **B.H.I** "។

**មាត្រា ២ :** វិទ្យាស្ថានប្រាយហូប មានទីតាំងស្ថិតនៅ ភូមិម៉ុងបារាំង ឃុំប្អេរ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣ :** វិទ្យាស្ថានប្រាយហូប ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ ។ វិទ្យាស្ថាននេះ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីចាប់ដំណើរការបាន ៦ ( ប្រាំមួយ ) ខែ ។

**មាត្រា ៤ :** វិទ្យាស្ថានប្រាយហូប មាន ពីរមហាវិទ្យាល័យ :

- មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍
- មហាវិទ្យាល័យ កសិកម្ម និងអភិវឌ្ឍជនបទ

ទៅអនាគតវិទ្យាស្ថាននេះ អាចបើកសាខា មហាវិទ្យាល័យ មុខជំនាញ ប្រភេទបណ្តុះបណ្តាលដទៃទៀត ឬប្តូរទីតាំងថ្មី ដោយរៀបចំសំណុំ បែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥ :** វិទ្យាស្ថានប្រាយហូប មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃវិទ្យាស្ថានប្រាយហូប ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថាន និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៦ :** នាយកវិទ្យាស្ថាន មានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថាននេះ និងធានាឱ្យមានសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម ។
- គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាល របស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់របស់រាជរដ្ឋាភិបាល សំដៅធានាគុណភាពអប់រំ ។
- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ស្របតាមការណែនាំ របស់ក្រសួងអប់រំ យុវជន និងកីឡា ។
- គោរពតាមកិច្ចសន្យាដែលវិទ្យាស្ថានប្រាយហូប នៅខេត្តកំពង់ឆ្នាំង បានសន្យាចំពោះក្រសួងអប់រំ យុវជន និងកីឡា ។
- ធ្វើរបាយការណ៍ អំពីការងារបណ្តុះបណ្តាល មកនាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។

**មាត្រា ៧ :** និស្សិតដែលបានរៀនចប់កម្មវិធីសិក្សា របស់វិទ្យាស្ថានប្រាយហូប និងទទួលបានជោគជ័យ ក្នុងការប្រឡង

ឱ្យដោយវិទ្យាស្ថានប្រាយហ្វូប ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី វិទ្យាស្ថានប្រាយហ្វូប បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និង វិទ្យាស្ថានប្រាយហ្វូប ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ ១៧ ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាខេត្តកំពង់ឆ្នាំង
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ